- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា   ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ..៥៥២.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការដូនមេដាយ សហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត ១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់មេដាយ **សហមេត្រី ថ្នាក់និយមមិត្ត** ជូនដល់ឯកឧត្តម LE DINH THANH ទីប្រឹក្សាស្ថានទូតវៀតណាមប្រចាំព្រះរាជាណាចក្រកម្ពុជា ទទួលបន្ទុកការងារសន្តិសុខ បានរួមសហប្រតិបត្តិការល្អជាមួយនាយកដ្ឋានសន្តិសុខផ្ទៃក្នុង ក្នុងការបង្ក្រាបបទល្មើសករណីចាប់ជំរិតមនុស្ស ជួញដូរគ្រឿងញៀន និងការទប់ស្កាត់អំពើភេរវកម្មព្រមទាំងបានជួយបណ្តុះបណ្តាលជំនាញដល់មន្ត្រីនគរបាលជាតិកម្ពុជា។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៥៣ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយ ស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជសរកត ១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ .-

ត្រូវបានបំពាក់មេដាយ **ស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនដល់នាយនគរបាល និងនាយនគរបាលជាតិជាន់ខ្ពស់ចំនួន ០៩ រូប នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ មានចិត្តសប្បុរសជួយឧបត្ថមថវិកាផ្ទាល់ខ្លួនដែលមានទឹកប្រាក់សរុបចំនួន ៣៣.៧៤៦ ដុល្លា (សាមសិបបីពាន់ប្រាំពីរយសែសិបប្រាំមួយដុល្លាសហរដ្ឋអាមេរិកគត់) ដើម្បីកសាងប៉ុស្តិ៍នគរបាលការពារព្រំដែនថ្មល់បំបែក-ប៉ុស្តិ៍នគរបាលការពារព្រំដែនបឹងសាត្វ ចំណុះវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៩១១-ជួសជុលការិយាល័យប្រឆាំងគ្រឿងញៀននិងទិញរថយន្ត ០២ គ្រឿង សំរាប់បំរើការងារក្នុងស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម ៖

ក. មេដាយ មាស ស្ថាបនាជាតិ:

១- លោកអនុសេនីយ៍ឯក រ៉ែម ដារ៉េត អត្តលេខ ៦០៨៦០ មេបញ្ជាការរងវរៈលេខ៩១១បានឧបត្ថមថវិកាចំនួន ១០.២៥០ដុល្លា

ខ. មេដាយ ប្រាក់ ស្ថាបនាជាតិ:

១- លោកអនុសេនីយ៍ឯក ជុំ អមរា អត្តលេខ ២២៦០៦ នាយរងការិយាល័យ បានឧបត្ថមថវិកាចំនួន ៥.២០០ដុល្លា

២- លោកអនុសេនីយ៍ឯក លឹម តេកផេង អត្តលេខ ៥៦១១១ នាយផ្នែក បានឧបត្ថមថវិកាចំនួន ៥.១៦០ដុល្លា

៣- លោកអនុសេនីយ៍ត្រី ពុត រុន អត្តលេខ ៣៥៧៧២ នាយរងប៉ុស្តិ៍វរលេខ៩១១ បានឧបត្ថមថវិកាចំនួន ៥.១០០ដុល្លា

គ. មេដាយ សំរិទ្ធ ស្ថាបនាជាតិ:

១- លោកវរសេនីយ៍ទោ សិទ្ធិ ឡោះ អត្តលេខ ០៩០៤៩ នាយការិយាល័យ បានឧបត្ថមថវិកាចំនួន ១.១៩៨ដុល្លា

២- លោកវរសេនីយ៍ត្រី ចាប សុផារិទ្ធ អត្តលេខ ១០២៨៩ នាយការិយាល័យ បានឧបត្ថមថវិកាចំនួន ១.៦០៧ដុល្លា

៣- លោកអនុសេនីយ៍ត្រី សួង សៅ អត្តលេខ ៣៩៧៩៧ នាយប៉ុស្តិ៍លេខ៩១១ បានឧបត្ថមថវិកាចំនួន ២.០១១ដុល្លា

៤- លោកព្រិន្ទបាលឯក អៀង រ៉ា អត្តលេខ ៥២០៦៥ នាយរងប៉ុស្តិ៍លេខ៩១១ បានឧបត្ថមថវិកាចំនួន ២.១០០ដុល្លា

៥- លោកព្រិន្ទបាលទោ គង់ ហេង អត្តលេខ ៥២០២៣ នាយរងប៉ុស្តិ៍លេខ៩១១ បានឧបត្ថមថវិកាចំនួន ១.១២០ដុល្លា

មាត្រា ២ ~ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៥៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសុវត្ថារា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយសុវត្ថារា ថ្នាក់ សេនា ជូននាយទាហាន ចំនួន ០២រូប ដែលមានស្នាដៃល្អក្នុងការបំពេញបេសកកម្ម រក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ លើវិស័យមនុស្សធម៌ នៅប្រទេសស៊ូដង់ ប្រទេសឆាដ និងអាហ្វ្រិកកណ្តាល កន្លងមក ដូចមានរាយនាមខាងក្រោម៖

១- វរសេនីយ៍ទោ ខាំ សេរីរិទ្ធ អត្តលេខ ០៣៧៦២០ នាយទាហានគាំទ្រថ្នាក់ជាតិ
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

២- វរសេនីយ៍ទោ នន យ៉ាម៉ារូ អត្តលេខ ២០២៨៧៦ ប្រធានក្រុមពេទ្យ(វេជ្ជបណ្ឌិត)
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៥៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមាសការងារ ជូននាយទាហាន នាយទាហានរង និងពលទាហាន ចំនួន ៨២រូប និងកងឯកភាពចំនួន ០២កង ដែលមានស្នាដៃល្អ ក្នុងការបំពេញបេសកកម្ម រក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ លើវិស័យមនុស្សធម៌ នៅប្រទេសស៊ូដង់ ប្រទេសឆាដ និងអាហ្វ្រិកកណ្តាល កន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-កងឯកភាព

១- កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

២- កងអនុសេនាតូចត្រួតពិនិត្យច្រកចេញចូលលេខ ៣០៦

ខ-បុគ្គល

១- វរសេនីយ៍ទោ ឈឹន ជំនិត	អត្តលេខ ០៤៥៨១៨	មេបញ្ជាការរង កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦
២-វរសេនីយ៍ត្រី មាឃ ទឹមចិន្តា	អត្តលេខ ០៣១៥០៧	ជំនួយការរដ្ឋបាល កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦
៣-វរសេនីយ៍ត្រី មិន សុវណ្ណ	អត្តលេខ ០៤៥៨២៧	ប្រធានក្រុមត្រួតពិនិត្យ កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៤-អនុសេនីយ៍ឯក	ង៉ែត	វណ្ណរិទ្ធ	អត្តលេខ ០៤៤៥២៩ ប្រធានក្រុមត្រួតពិនិត្យ កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦
៥-អនុសេនីយ៍ឯក	ឌិក	សេរី	អត្តលេខ ០៤៤៥៣៦ ជំនួយការផ្នែកសម្របសម្រួល កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦
៦-អនុសេនីយ៍ឯក	មា	ផលគន្ធ	អត្តលេខ ០៨១៩៣៦ នាយទាហានសម្របសម្រួល កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦
៧-អនុសេនីយ៍ឯក	យូ	វិបុល	អត្តលេខ ០២៧១២៤ ជំនួយការសង្គ្រោះ កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥
៨-អនុសេនីយ៍ឯក	នុត	ហុន	អត្តលេខ ០២៧១៣៤ ជំនួយការបោសសំអាតមីន កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥
៩-អនុសេនីយ៍ឯក	សែម	សំបូរ	អត្តលេខ ០២៧១៣៨ អនុប្រធានក្រុមបោសសំអាតមីន កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥
១០-អនុសេនីយ៍ឯក	ចេនឡា	រដ្ឋា	អត្តលេខ ០៤៧៨៧៧ ប្រធានក្រុមកំទេចគ្រឿងផ្ទុះ កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥
១១- អនុសេនីយ៍ឯក	នី	ចន្ទីរដ្ឋ	អត្តលេខ ១៥៦៧១០ ជំនួយការសង្គ្រោះ កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥
១២- អនុសេនីយ៍ទោ	អ៊ុម	រិទ្ធី	អត្តលេខ ០២៤៨៧០ ជំនួយការត្រួតពិនិត្យ កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦
១៣- អនុសេនីយ៍ទោ	សាង	ដួង	អត្តលេខ ០៤៨៤៦០ ប្រធានផ្នែកត្រួតពិនិត្យទី២ កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦
១៤- អនុសេនីយ៍ទោ	ប៉ាន	រតនះ	អត្តលេខ ០៤៨៤៨៧ ប្រធានក្រុមត្រួតពិនិត្យ កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦
១៥- អនុសេនីយ៍ទោ	ផាន់	បញ្ញា	អត្តលេខ ១០២៣៣១ ជំនួយការត្រួតពិនិត្យ កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦
១៦- អនុសេនីយ៍ទោ	អាត	សំអឿន	អត្តលេខ ១៣៩៩៣១ ប្រធានផ្នែកត្រួតពិនិត្យទី១ កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦
១៧- អនុសេនីយ៍ទោ	ហេង	វ៉ាម៉ូ	អត្តលេខ ១៦៨៤៥៥ ជំនួយការបើកបរ កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦
១៨- អនុសេនីយ៍ទោ	សែម	វ័ត្ថនាង	អត្តលេខ ០៣៦៦០២ ជំនួយការបើកបរ កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥
១៩- អនុសេនីយ៍ទោ	ពិន	សារ៉េត	អត្តលេខ ០៤៧០២៨ ជំនួយការបច្ចេកទេស កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥
២០- អនុសេនីយ៍ទោ	ស៊ឹម	សុធារ៉ា	អត្តលេខ ០៦៥៩៤៥ ប្រធានក្រុមបោសសំអាតមីន កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥
២១- អនុសេនីយ៍ទោ	ស៊ូ	អៀងឡេង	អត្តលេខ ០៦៨៩៥៦ ជំនួយការបោសសំអាតមីន កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥
២២- អនុសេនីយ៍ទោ	ជុត	ចាន់ណា	អត្តលេខ ១៣៥៨៩១ ជំនួយការភស្តុភារ កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

២៣- អនុសេនីយ៍ទោ លី ចំណាន អត្តលេខ ១៨៦៦០២ ជំនួយការបើកបរ
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

២៤- អនុសេនីយ៍ទោ ចក់ ស៊ីថុល អត្តលេខ ២២១៣៤០ ប្រធានក្រុមបោសសំអាតមីន
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

២៥- អនុសេនីយ៍ត្រី ជាតិ សុបញ្ញា អត្តលេខ ០៤៨៤៨៥ ប្រធានក្រុមត្រួតពិនិត្យ
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

២៦- អនុសេនីយ៍ត្រី គ្រួច សុជាត អត្តលេខ ១៣១៦១០ ជំនួយការបើកបរ
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

២៧- អនុសេនីយ៍ត្រី អាន ឡឹម អត្តលេខ ០៧៧២១៣ ជំនួយការពេទ្យ
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

២៨- អនុសេនីយ៍ត្រី អ៊ុំ កុសល្យ អត្តលេខ ១៦៣២០៥ ជំនួយការជាំស្ល
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

២៩- នាយចំណង់ ម៉ុត យ៉ឺន អត្តលេខ ០៦៥៦២៦ ជំនួយការបោសសំអាតមីន
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៣០- នាយចំណង់ សៀង គន្ធា អត្តលេខ ១៦០៨០៧ ជំនួយការបោសសំអាតមីន
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៣១- នាយចំណង់ លុក សារ៉ាយ អត្តលេខ ២០០៧៨២ នាយទាហានគាំទ្រថ្នាក់ជាតិ
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៣២- នាយចំណង់ សាន វ៉ាន់ អត្តលេខ ២០០៨៨៩ ជំនួយការបោសសំអាតមីន
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៣៣- នាយចំណង់ ប៊ុន ធានី អត្តលេខ ២០០៧៨១ ជំនួយផ្នែកផែនការ
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៣៤- នាយចំណង់ ប៊ុនលី មុន្នីរៈ អត្តលេខ ២០០៧៩៣ ជំនួយការផ្នែកផែនការ
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៣៥- នាយចំណង់ ឌុង សុគន្ធដានី អត្តលេខ ២០០៧៩៤ ជំនួយត្រួតពិនិត្យ
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៣៦- នាយចំណង់ ប៉ុល ប៊ុនថន អត្តលេខ ២០០៧៩៥ ប្រធានក្រុមត្រួតពិនិត្យ
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៣៧- នាយចំណង់ ហ៊ិន សូឡី អត្តលេខ ២០០៧៩៦ ជំនួយការវិទ្យុទាក់ទង
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៣៨- នាយចំណង់ អ៊ី ស៊ីផាន់ណា អត្តលេខ ២០០៨០០ ប្រធានក្រុមត្រួតពិនិត្យ
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៣៩- នាយចំណង់ គង់ ចាន់ណល់ អត្តលេខ ២០០៨០៩ ប្រធានផ្នែកសម្របសម្រួល
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៤០- នាយចំណង់ [redacted] ហេងឡាយ អត្តលេខ ២០០៨១៤ ប្រធានផ្នែកផែនការ
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៤១- នាយចំណង់ ឃី ភិរម្យ អត្តលេខ ២០០៨១៥ ប្រធានក្រុមត្រួតពិនិត្យ
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៤២- នាយចំណង់ អ៊ើល ភារម្យ អត្តលេខ ២០០៨២៧ ជំនួយការផ្នែកសម្របសម្រួល
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៤៣- នាយចំណង់ ឡឹក ចំរើន អត្តលេខ ២០០៨២៩ ជំនួយការត្រួតពិនិត្យ
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៤៤- នាយចំណង់ ហ៊ាង វិបុល អត្តលេខ ២០០៨៣៤ ជំនួយការបើកបរ
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៤៥- នាយចំណង់ ស៊ាង សីហា អត្តលេខ ២០០៨៣៥ ជំនួយការត្រួតពិនិត្យ
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៤៦- នាយចំណង់ ឃឹម ណារ៉េន អត្តលេខ ២០០៨៧៨ ជំនួយការបើកបរ
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៤៧- នាយចំណង់ សែម សំ អត្តលេខ ២០០៨៨៧ ជំនួយការបើកបរ
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៤៨- នាយចំណង់ ស៊ុម ភន អត្តលេខ ២០០៨៨៨ ជំនួយការផ្នែកផែនការ
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៤៩- ព្រិន្ទបាលឯក ឈាម វិសាល អត្តលេខ ១៩៦៤៩៧ ប្រធានផ្នែករដ្ឋបាល
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៥០- ព្រិន្ទបាលឯក ស្រេង សារី អត្តលេខ ១៦៣២១២ ជំនួយការត្រួតពិនិត្យ
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៥១- ព្រិន្ទបាលឯក អឹង សុខមាន អត្តលេខ ១៦៣២៥២ ជំនួយការបើកបរ
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៥២- ព្រិន្ទបាលឯក គី ស៊ុនឌីណា អត្តលេខ ១៦៣៣២៨ ជំនួយការបើកបរ
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៥៣- ព្រិន្ទបាលឯក វ៉ែត ប៉េងហាក់ អត្តលេខ ០៦៤៤៧៤ បុគ្គលិក កំទេចគ្រឿងផ្ទុះ
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៥៤- ព្រិន្ទបាលឯក ឡោះ សាហ្វីអ៊ី អត្តលេខ ០៧០៥៧៣ បុគ្គលិក វិទ្យុទាក់ទង
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៥៥- ព្រិន្ទបាលឯក រស់ ឆេងណាង អត្តលេខ ០៧០៨១០ បុគ្គលិក បោសសំអាតមីន
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៥៦- ព្រិន្ទបាលឯក អ៊ុយ សុផល អត្តលេខ ០៨៨៧៧៣ បុគ្គលិកបើកបរ
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៥៧- ព្រិន្ទបាលឯក អួន ភារម្យ អត្តលេខ ១០២១៦១ បុគ្គលិកកំទេចគ្រឿងផ្ទុះ
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៥៨- ព្រិន្ទបាលទោ ជា រិទ្ធី អត្តលេខ ០៧០៥៩៥ បុគ្គលិកពេទ្យ
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៥៩- ព្រិន្ទបាលទោ ហេង ណារិន អត្តលេខ ០៩៣៧៦១ ជំនួយការផ្នែកសម្របសម្រួល
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៦០- ពលបាលឯក នាង អឿន អត្តលេខ ១៩៧៧៩២ ជំនួយការផ្នែកផែនការ
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៦១- ពលបាលឯក យន់ វាសនា អត្តលេខ ០៨៨០១៣ បុគ្គលិកពេទ្យ
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៦២- ពលបាលឯក ឈឿង ឈឿម អត្តលេខ ១០២៣៨៧ បុគ្គលិកបោសសំអាតមីន
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៦៣- ពលបាលទោ អ៊ុម ស្រ៊ុម អត្តលេខ ០៨៨៨៨៦ បុគ្គលិកបោសសំអាតមីន
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៦៤- ពលបាលទោ សូ សាវន អត្តលេខ ០៨៨៨៩០ បុគ្គលិកបោសសំអាតមីន
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៦៥- ពលបាលត្រី ប៉ែន រតនា អត្តលេខ ២០០៧៩២ បុគ្គលិកបោសសំអាតមីន
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៦៦- ពលបាលត្រី ណន នឿន អត្តលេខ ២០០៨០៦ បុគ្គលិកបើកបរ
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៦៧- ពលបាលត្រី គីម ធួន អត្តលេខ ២០០៨៧៣ បុគ្គលិកសង្គ្រោះ
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៦៨- ពលបាលត្រី នាង ដារ៉ា អត្តលេខ ២០០៨៧៧ បុគ្គលិកបើកបរ
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៦៩- ពលបាលត្រី ឆាន សាមីន អត្តលេខ ២០០៨៨០ បុគ្គលិកបោសសំអាតមីន
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៧០- ពលបាលត្រី ស៊ាង វិច្ឆិកា អត្តលេខ ២០០៨៨១ បុគ្គលិកបើកបរ
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៧១- ពលបាលត្រី នោម រដ្ឋា អត្តលេខ ២០០៨៨៣ បុគ្គលិកបោសសំអាតមីន
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៧២- ពលបាលត្រី ឆេង សំអុល អត្តលេខ ២០០៩១៥ បុគ្គលិកបោសសំអាតមីន
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៧៣- ពលបាលត្រី ចឹក សម្បត្តិ អត្តលេខ ២០០៩៤៤ បុគ្គលិកបោសសំអាតមីន
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៧៤- ពលបាលត្រី កាង ប៊ុនធឿន អត្តលេខ ២០០៩៥៤ បុគ្គលិកបោសសំអាតមីន
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៧៥- ពលបាលត្រី ណោន សុវណ្ណារ៉ា អត្តលេខ ២០០៩៧៩ បុគ្គលិកបោសសំអាតមីន
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៧៦- ពលបាលត្រី លេង ឈុនលី អត្តលេខ ២០០៩៨៣ បុគ្គលិកបោសសំអាតមីន
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៧៧- ពលបាលត្រី ឃូ រដ្ឋា អត្តលេខ ២០០៩៩២ បុគ្គលិកបោសសំអាតមីន
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៧៨- ពលបាលត្រី ឈួន បូណា អត្តលេខ ២០១០០៩ បុគ្គលិកបើកបរ
កងអនុសេនាតូចបោសសំអាតមីនលេខ ៤០៥

៧៩- ពលបាលត្រី សន ណាប អត្តលេខ ២០០៨៦៨ ជំនួយការបើកបរ
កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

៨០- ពលបាលត្រី	ឆោម	បូឡា	អត្តលេខ ២០០៨៩១	ជំនួយការបើកបរ កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦
៨១- ពលបាលត្រី	អ៊ិន	ចំណាប់	អត្តលេខ ២០០៨៩៥	ជំនួយការបើកបរ កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦
៨២- ពលបាលត្រី	អាត	មករា	អត្តលេខ ២០០៨៩៩	ជំនួយការត្រួតពិនិត្យ កងអនុសេនាតូចត្រួតពិនិត្យច្រកចេញ ចូលលេខ៣០៦

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ HSR

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ ឧសភា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

អន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៥៧ អនុក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យ លេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១: តែងតាំងលោក **ពុត សាមិត្ត** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ជំនួសលោក **លាង ខួនលី** ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៣៤៦ ឧរថ.ភក.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែឧសភា ឆ្នាំ២០១០

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ៨៩៧ /០៩ គ.វ.ក ចុះថ្ងៃទី១៧.០៣.២០០៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ម៉ីង ជៀន (ខេមបូឌា) ចុះថ្ងៃទី១១.០៣.២០១០

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន ម៉ីង ជៀន (ខេមបូឌា) តំណាងដោយ លោក HE JIANPING សញ្ជាតិចិន អាយុ៥៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G23844344 ចុះថ្ងៃទី១០.០៧.២០០៧ មានអាសយដ្ឋានបច្ចុប្បន្ន៖ No.1025, Shi Lin Bai Rd., Khan Song Jiang, Shanghai City, China ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

-ឈ្មោះផលិតផល	លេខចុះបញ្ជីផលិតផល ISIC Code
សម្លៀកបំពាក់	៣២២០

-ផ្លាកឈ្មោះរោងចក្រ ៖"ម៉ីង ជៀន (ខេមបូឌា) (MING JIAN (CAMBODIA) CO., LTD.)"

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមាន ប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬ ករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: -ប្រកាសលេខ៧៣៧ ឧរថ.កឧ.ប្រក ចុះថ្ងៃទី២៥.០៨.២០០៨ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ភុង អាន អ៊ិនដាសស្រ្ទៀល (PONG AN INDUSTRIAL CO., LTD.) ដែលមានទីតាំងស្ថិតនៅ ភូមិត្រពាំងរំចេក សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

ប្រការ១៦: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

លេខ : ៣៤៣ ឧសថ.ឧក-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១០

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ៦៧៥ /១០ គ.វ.ក ចុះថ្ងៃទី៣០.០៣.២០១០ របស់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន សៅថ៍ បាយ អ៊ិនធើប្រាយស៍ ក្វ អិលធីឌី ចុះថ្ងៃទី០២.០៤.២០១០

សម្រេច

<u>ប្រការ១</u>: អនុញ្ញាតឲ្យក្រុមហ៊ុន សៅថ៍ បាយ អ៊ិនធើប្រាយស៍ ក្វ អិលធីឌី តំណាងដោយ លោកស្រី LI XIULAN សញ្ជាតិចិន អាយុ៦៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G30300810 ចុះថ្ងៃទី ១៨.០៧.២០០៨ មានអាសយដ្ឋានបច្ចុប្បន្នៈ No .68 Ziyou Blvd. Changchun ,JL China ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

-ឈ្មោះផលិតផល លេខចុះបញ្ជីផលិតផល ISIC Code

សម្លៀកបំពាក់ ៣២២០

-ផ្លាកឈ្មោះរោងចក្រ ៖ " សៅថ៍ បាយ អ៊ិនធើប្រាយស៍ ក្វ អិលធីឌី (SOUTH BAY ENTERPRISE CO., LTD.)"

-ទីតាំងរោងចក្រ ៖ *" អាគារ E និង អាគារ F សួនឧស្សាហកម្មខ្សេនៈ ផ្លូវចោមចៅ ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ"*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាដំដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល។។។

១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅពេលដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាម បទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការ ចុះបញ្ជីផលិតផល ។

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាម

មាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមាន ប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានទាន់ហេតុ អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: ប្រកាសលេខ១៧២ ឧក.ប្រក ចុះថ្ងៃទី០២.០៣.១៩៩៨ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់នាំចេញ របស់ក្រុមហ៊ុន សៅធ៍ បាយ អ៊ិនធើប្រាយស៍ ខូអិលធីឌី (SOUTH BAY ENTERPRISE CO., LTD.) ដែលមានទីតាំងស្ថិតនៅ តាមបណ្តោយផ្លូវពីប៉ុស្តិ៍វិទ្យុស្ទឹងមានជ័យទៅចោមចៅ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ និង ប្រកាសលេខ ១៦៨ ឧរថ.កឧ.ប្រក ចុះថ្ងៃទី០១.០៣.២០០៤ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់នាំចេញ របស់ក្រុមហ៊ុន ហ្គោលដេន ក្រោន (ខេមបូឌា) (GOLDEN CROWN (CAMBODIA) CO., LTD.) ដែលមានទីតាំងស្ថិតនៅ អាគារ F សួនឧស្សាហកម្មវត្តស្លែង ផ្លូវចោមចៅ ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១៥: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

ប្រការ១៦: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនប្រាប់"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៣៤៤ ឧរ៉ថ.កឧ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ៣៨៣ /១០ គ.វ.ក ចុះថ្ងៃទី២៨.០២.២០១០ របស់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អានហ្វិល ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ចុះថ្ងៃទី១៥.០២.២០១០

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន អានហ្វិល ហ្គាមេន ហ្វេកធើរី (ខេមបូឌា) តំណាងដោយ លោកស្រី LEE WAI SHAN សញ្ជាតិចិន អាយុ៣០ឆ្នាំ កាន់លិខិតឆ្លងដែនលេខ KJ0056019 ចុះថ្ងៃទី ២១.០៥.២០០៨ មានអាសយដ្ឋាន បច្ចុប្បន្នៈFLAT-B, 6/FL. GEE FAT FTY, BLDG 78 FUK TSUN STREET, TAIKOKTSUI KOWLOON, HONG KONG ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រលើមុខសញ្ញា ដូចខាងក្រោម ៖

-ឈ្មោះផលិតផល	លេខចុះបញ្ជីផលិតផលISICCode
សម្លៀកបំពាក់	៣២២០

ភព

-ផ្លាកឈ្មោះរោងចក្រ ៖ " *អានហ៊្វុល ហ្គាមេន ហ្វេកធើរី (ខេមបូឌា) (ANFUL GARMENTS FACTORY (CAMBODIA))* "

-ទីតាំងរោងចក្រ ៖ *"ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ"*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាដ៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេសដែលត្រូវបាន កំណត់ ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មាន ជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋាន ឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសបញ្ញត្តិ តាមមាត្រា៩៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាម បទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការ ចុះបញ្ជីផលិតផល ។

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមាន ប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលពាល់ ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: អគ្គនាយកដ្ឋានឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

ប្រការ១៥: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលារាជធានីភ្នំពេញ ,
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០៣១ ស.ណ.ព.ក-ឱសថ

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០១០

លិខិតចូល
ថ្ងៃទី១៩....ខែឧសភាឆ្នាំ20១០

ប្រកាស

ស្តីពី

បែបបទ និងលក្ខខណ្ឌក្នុងការផ្សព្វផ្សាយគ្រឿងសម្អាង

រដ្ឋមន្ត្រី ក្រសួងសុខាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ កញ្ញា ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រម នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញ ព្រះរាជក្រម ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី ១៧ មិថុនា ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ ស្តីពី ការគ្រប់គ្រងឱសថ

-បានឃើញ ព្រះរាជក្រម នស/រកម/១២០៧/០៣៧ ចុះថ្ងៃទី ២៨ ធ្នូ ២០០៧ ប្រកាសឱ្យប្រើច្បាប់ ស្តីពី វិសោធនកម្ម ច្បាប់ ស្តីពី ការគ្រប់គ្រងឱសថ

-បានឃើញ អនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ តុលា ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល

-បានឃើញ អនុក្រឹត្យលេខ ១៦២អនក្រ.បក ចុះថ្ងៃទី ២៨ សីហា ២០០៨ ស្តីពីការគ្រប់គ្រងគ្រឿងសម្អាង

-និងយោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល ។

ស ម្រេ ច

ប្រការ១ : ការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងសម្អាងគ្រប់ប្រភេទ តាមរយៈទូរទស្សន៍ វិទ្យុ សារព័ត៌មាន ទស្សនាវដ្តី ព្រឹត្តិប័ត្រវេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ ប័ណ្ណប្រកាសរូបភាព សិក្ខាសាលា ទិវាវេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ ឬតាមរូបភាពផ្សេងៗទៀតអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

ប្រការ២ : គ្រឿងសម្អាងគ្រប់ប្រភេទ អាចសុំធ្វើការផ្សព្វផ្សាយបាន លុះត្រាតែមានលេខបញ្ជិកាចេញដោយក្រសួងសុខាភិបាល ។

អត្ថបទ និង រូបភាពដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងសម្អាង ត្រូវឆ្លងការត្រួតពិនិត្យ និងមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

ប្រការ៣ : ការសុំផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងសម្អាង ត្រូវបំពេញសំណុំលិខិត ដូចខាងក្រោម :

ក-ករណីផ្សព្វផ្សាយតាមទូរទស្សន៍ ឬវិទ្យុ

-ពាក្យសុំផ្សព្វផ្សាយ និង កិច្ចសន្យា	១ ច្បាប់ (មានគំរូ)
-វិញ្ញាបនប័ត្រប្រវេទនី (ថតចម្លង)	១ ច្បាប់
-សេចក្តីព្រាងអត្ថបទផ្សព្វផ្សាយ	១ ច្បាប់
-កាសែតវីដេអូ DVD ឬ VCD ឬ CD ជា Spot គំរូ	១ ឯកតា
-គ្រឿងសម្អាងគំរូ	១ ឯកតា

ខ-ករណីផ្សព្វផ្សាយតាមសារព័ត៌មាន ឬទស្សនាវដ្តី ឬប្រតិទិន ឬសៀវភៅផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗ ឬប័ណ្ណប្រកាសរូបភាព ឬខិត្តប័ណ្ណ ឬសម្ភារៈប្រើប្រាស់ផ្សេងៗ

-ពាក្យសុំផ្សព្វផ្សាយ និង កិច្ចសន្យា	១ ច្បាប់ (មានគំរូ)
-វិញ្ញាបនប័ត្រប្រវេទនី (ថតចម្លង)	១ ច្បាប់
-សេចក្តីព្រាងអត្ថបទ និងរូបភាពផ្សព្វផ្សាយ	១ ច្បាប់
-គ្រឿងសម្អាងគំរូ	១ ឯកតា

គ-ករណីធ្វើសិក្ខាសាលា ឬប្រជុំគុម្ពល ឬក្នុងកម្មវិធីផ្សេងៗតាមប៉ុស្តិ៍វិទ្យុ-ទូរទស្សន៍

-ពាក្យសុំផ្សព្វផ្សាយ និងកិច្ចសន្យា	១ ច្បាប់ (មានគំរូ)
-វិញ្ញាបនប័ត្រប្រវេទនី (ថតចម្លង)	១ ច្បាប់
-កម្មវិធី	១ ច្បាប់

ប្រការ៤ : លិខិតអនុញ្ញាតផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្តី មានសុពលភាពរយៈពេល ៦ខែ លើកលែងតែប្រតិទិន ឬខិត្តប័ណ្ណ ឬសម្ភារៈប្រើប្រាស់ផ្សេងៗ ដែលមានសុពលភាព ១ឆ្នាំ ។ សាមីជនអាចសុំបន្តការផ្សព្វផ្សាយសារឡើងវិញ ១ខែមុនពេលអស់សុពលភាព ។

ប្រការ៥ : ការផ្សព្វផ្សាយដែលត្រូវហាមឃាត់ :

-ប្រើឧគ្ឃោសនស័ព្ទតាមទីសាធារណៈ រោងល្ខោន រោងកុន ផ្សារណាត់

-បិទតាមទូទូរស័ព្ទសាធារណៈ មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ

-ធ្វើជាបដាចងកាត់ទទឹងថ្នល់ តាមបង្គោលភ្លើង ឬទីសាធារណៈ ឬតាមអាគារផ្សេងៗ

-បិទក្បែរស្លាកសញ្ញាឱសថស្ថាន-រង ឬធ្វើជាស្លាកសញ្ញាឱសថស្ថាន-រង

-ឬតាមរូបភាពផ្សេងៗទៀត ដែលគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

ប្រការ៦ : ក្រសួងសុខាភិបាលមានសិទ្ធិដកហូតវិញនូវលិខិតអនុញ្ញាតផ្សព្វផ្សាយ ក្នុងករណីពិនិត្យឃើញថា :

-ខ្លឹមសារ និងរូបភាពផ្សព្វផ្សាយមានលក្ខណៈខុសពីការយល់ព្រមរបស់ក្រសួងសុខាភិបាល

-ឬផលិតផលនោះអាចបង្កគ្រោះថ្នាក់ដល់សុខភាពតាមការផ្តល់ព័ត៌មានពីក្រសួងមានសមត្ថកិច្ច ។

ប្រការ៧ : ការប្រព្រឹត្តល្មើសនឹងប្រកាសនេះត្រូវផ្តន្ទាទោសតាមទោសបញ្ញត្តិដែលមានចែងក្នុងច្បាប់ ស្តីពីការគ្រប់គ្រងឱសថ ។

